

# សៀវភៅពណ៌មាស

ស្រី សម្ផស្ស
Eva Calonder

Let's Read
The Asia Foundation



វគ្គទី១ សៀវភៅនៃចំណេះដឹង រស់កើតក្នុងគ្រួសារក្រីក្រមួយ។រាល់ថ្ងៃក្មេងប្រុសនេះត្រូវធ្វើការងារយ៉ាងធ្ងន់ធ្ងរដើម្បីចិញ្ចឹមជីវិត។នៅក្បែរផ្ទះគេមានគ្រួសារសេដ្ឋីស្តុកស្តម្ភមួយហើយគ្រួសារនោះមានកូនប្រុសម្នាក់ឈ្មោះបុត្រដែលជាក្មេងទម្រើសបំផុត។ ថ្ងៃមួយដូនចាស់ម្នាក់ទំនងជាអ្នកចេះដឹងបានមកដល់ផ្ទះគ្រួសារសេដ្ឋី។គាត់បង្ហាញសៀវភៅចំណាស់ដ៏ក្រាស់មួយក្បាលដែល មានក្របពណ៌ទឹកមាស។គាត់ពោលអះអាង៖ -សៀវភៅនេះកត់ត្រាចំណេះដឹងទាំងឡាយដែលមានជាយូរលង់ណាស់មកហើយ។បើអ្នកណាបានអានវាគេនឹងមានចំណេះដឹងខ្ពង់ខ្ពស់ហើយថែមទាំងអាចពូកែត្រិះរិះពិចារណាទៀតផង។

សេដ្ឋីបើកសៀវភៅពណ៌មាសមើលហើយគិតក្នុងចិត្តៈ -បើយើងទិញសៀវភៅនេះឱ្យបុត្រកូនរបស់យើងនឹងអាចក្លាយទៅជាមនុស្សដ៏ប្រពៃម្នាក់។ គាត់ក៏ព្រមទិញវាទោះជាសៀវភៅនេះមានតម្លៃខ្ពស់ក៏ដោយ។



បន្ទាប់មកសេដ្ឋីហៅបុត្រមកជួបនិងប្រាប់៖ -កូនឯងត្រូវអានសៀវភៅនេះយ៉ាងហោចណាស់មួយថ្ងៃមួយទំព័រ។រាល់ល្ងាចថ្ងៃសៅរ៍ឯងសរសេរសង្ខេបពីអ្វីដែលបានអានឱ្យពុកមើល។បើឯងមិនធ្វើទេពុកនឹងដាក់ពិន័យឯង។ បុត្រជាក្មេងកម្ជិល។គេចូលចិត្តដើរលេងជាង។គេឧស្សាហ៍គេចសាលាណាស់។គាប់ជួនព្រឹកនោះបុត្រជួបរស់ដោយចៃដន្យហើយគេក៏មានគំនិតមួយភ្លាម។គេស្រែកហៅ៖ -អ៊ុំរស់! តើឯងចេះអានអក្សរទេ?



-□□□□□! ខ្ញុំធ្លាប់បានរៀនអក្សរនៅវត្តដែរ។ខ្ញុំចង់រៀនតែ ខ្ញុំត្រូវឈប់ព្រោះពុកម៉ែខ្ញុំគិតថាកូនអ្នកក្ររៀនទៅគ្មានបានអីទេ ខាតតែពេលឥតប្រយោជន៍។ -ឯងមានសំណាងមែន! នៅផ្ទះខ្ញុំ វិញអ្វីៗផ្ទុយពីនេះទាំងស្រុង។ប៉ុន្តែបើឯងចង់រៀនយើងដោះដូរ គ្នារឿងមួយ៖ឯងអានជំពូកទីមួយ ក្នុងសៀវភៅពណ៌មាសនេះ ជំនួសខ្ញុំហើយសរសេរសង្ខេបខ្លឹមសារ



រួចយកវាមកឱ្យខ្ញុំនៅថ្ងៃសៅរ៍ក្រោយ។ចាំខ្ញុំឱ្យលុយព្រមទាំងនំចំណីឆ្ងាញ់ៗទៅឯង។ រស់រារែកក្នុងចិត្តប៉ុន្តែដោយសារត្រូវការប្រាក់គេក៏យល់ព្រមតាមសំណើរបស់បុត្រ។ មួយអាទិត្យក្រោយមកសេដ្ឋីសួររកការងារពីកូនដូចសំដីគាត់មែន។បុត្របង្ហាញកិច្ចការដែលរស់បានសរសេរទៅឱ្យឪពុក។គាត់គ្មានសង្ស័យអ្វីទាំងអស់ហើយសរសើរកូន៖ -ល្អ! ពុកសប្បាយចិត្តណាស់ដោយឥឡូវឃើញឯងចេះធ្វើកិច្ចការបែបនេះ! ល្បិចនេះចេះតែបន្តរហូតក្លាយជាទម្លាប់៖រៀងរាល់សប្តាហ៍រស់ត្រូវអានសៀវភៅនិងសង្ខេបខ្លឹមសារឱ្យបុត្រ។



ពីដំបូងរស់មានការធុញថប់នឹងកិច្ចការនេះដែរ។គេមិនចូល
ចិត្តការកុហកទេតែគេត្រូវទ្រាំដើម្បីប្រាក់និងនំចំណី។ ប៉ុន្តែ
បន្តិចម្តងៗរស់ក៏ចាប់ផ្តើមជក់ចិត្តអានសៀវភៅពណ៌មាសនេះ
នៅរៀងរាល់ល្ងាចបន្ទាប់ពីការងារស្រែចម្ការដ៏នឿយហត់។ក្នុង
ទំព័រ នីមួយៗរស់អាចស្វែងយល់ពីពិភពថ្មីៗហើយមានតែភាព
ងោកងុយតែម្យ៉ាងគត់ដែលអាចកាត់ផ្តាច់គេចេញពីអំណាននេះ
បាន។



វគ្គទី២ជោគជ័យរបស់បុត្រ ច្រើនឆ្នាំកន្លងផុតទៅក្មេងទាំងពីរធំពេញរូបរាងហើយក្លាយជាមិត្តនឹងគ្នា។រស់តែងចងចាំគុណរបស់បុត្រដែលបានផ្តល់ឱកាសឱ្យគេបានរៀនសូត្រ។ល្ងាចមួយបុត្រទៅរករស់ហើយនិយាយទាំងខ្វល់ខ្វាយ៖ -ព្រះរាជានឹងរៀបចំពិធីប្រលងជ្រើសរើសទីប្រឹក្សាម្នាក់។ពុកចង់ឱ្យខ្ញុំប្រលងជាប់ជាដាច់ខាត។ -កុំបារម្ភអី! ខ្ញុំនឹងទៅប្រលងជំនួសឯង។ រស់នឹងជួយដល់បុត្រជាថ្មីម្តងទៀត។នោះជាការប្រលងប្រជែងដ៏សែនលំបាកមួយព្រោះគេប្រមូលផ្តុំបេក្ខជនមកពីគ្រប់ទិសទីក្នុងអាណាចក្រ។រស់ខំអានសៀវភៅពណ៌មាសឡើងវិញជាច្រើនថ្ងៃ។ថ្ងៃកំណត់មកដល់នាយក្លែងខ្លួនជាកូនសេដ្ឋីទៅចូលរួម

ប្រលងនិង ដាក់ឈ្មោះបុត្រនៅលើកិច្ចការរបស់ខ្លួន។ មិនយូរ
ប៉ុន្មានលទ្ធផលត្រូវបានប្រកាសហើយបុត្រត្រូវតែងតាំងជាទី
ប្រឹក្សាមួយរូបរបស់ព្រះរាជា។



ព្រះរាជាមានបុត្រីមួយអង្គដ៏ឆ្លាតវៃនិងមានរូបសម្ផស្សយ៉ាង
ស្រស់ស្អាតព្រះនាមបញ្ចនាថ។ព្រះនាងសព្វព្រះទ័យរាប់អាន
អ្នកចេះដឹងណាស់។ដោយការចង់ដឹងព្រះនាងសុំយកកិច្ចការ
ប្រលងរបស់ទីប្រឹក្សាថ្មីមកទត។ព្រះនាងអានវាព្រមទាំងឧទាន៖
-អ្ហ៎! នេះពិតជាចម្លើយដ៏ឈ្លាសវៃមែនឯអក្សរក៏សរសេរបាន
ស្អាតទៀត! ខ្ញុំចង់ស្គាល់លោកទីប្រឹក្សាថ្មីនេះណាស់។ ហេតុ
ដូចនេះព្រះនាងបញ្ចនាថអញ្ជើញបុត្រឱ្យចូលគាល់៖ -សួស្ដី
លោកបុត្រ! តើលោកអាចជួយសរសេរពាក្យជូនពរមួយឃ្លា
សម្រាប់ថ្ងៃចម្រើនព្រះជន្មបិតាខ្ញុំបានទេ



បុត្រមានមោទនភាពនឹងការផ្តល់កិត្តិយសរបស់ព្រះនាងជាខ្លាំង។គេតាំងចិត្តក្លាហានហើយសរសេរ៖ ខ្ញុំជូនព បិដាឱ្យមានសុខភាបល្អ!! ក្សត្រីស្ទើរតែមិនជឿភ្នែកខ្លួនឯង។ព្រះនាងគិតក្នុងចិត្ត៖«ឃ្លានេះសាមញ្ញណាស់និងសរសេរខុសច្រើនទៀត! ហើយចុះអក្សរអ្វីក៏គគ្រិចម្ល៉េះ!»។ ព្រះនាងមិនយល់រឿងនេះទាល់តែសោះ។ទ្រង់ចាប់ផ្តើមសង្ស័យលើបុត្រហើយសម្រេចចិត្តធ្វើការតាមដានមួយ។



វគ្គទី៣ ការសង្ស័យរបស់ព្រះនាង ប៉ុន្មានថ្ងៃក្រោយមកទៀត ព្រះនាងបញ្ចនាថអញ្ជើញបុត្រឱ្យរួមដំណើរ កម្សាន្តនៅតាមឆ្នេរសមុទ្រដែលស្ថិតនៅក្បែររាជវាំង។ពេលសម្លឹងទៅសមុទ្រ ព្រះនាងសួរបុត្រ៖ -តើលោកបុត្រដឹងទេហេតុអ្វីក៏សមុទ្រមានពណ៌ខៀវ? -□□... ព្រះនាងចាំពេលក្រោយទូលបង្គំនឹងទូលថ្វាយបានទេ? ពេលនេះទូលបង្គំមានកិច្ចការប្រញាប់មួយនៅឯរាជវាំង។ នាយបុត្រចាកចេញទៅក្រោមក្រសែភ្នែកសង្ស័យរបស់ព្រះនាងដែល សម្រេចថានឹងតាមដានគេ។ដូចជាលើកមុនៗដែរ គេរកជំនួយម្តងទៀតពីរស់ដែលដឹងនូវចម្លើយពីសៀវភៅពណ៌មាស៖ -បើសមុទ្រពណ៌ខៀវនោះព្រោះតែមេឃមានពណ៌ខៀវ!

មេឃជះពន្លឺលើសមុទ្រហើយផ្តល់ពណ៌ទៅឱ្យសមុទ្រ។ពេលមេឃស្រទំសមុទ្រក៏ប្រែពណ៌ឡើងក្រមៅដែរ។ បុត្រចាកចេញទៅវិញទាំងធូរស្បើយចិត្ត។គេប្រញាប់ត្រលប់ទៅឆ្នេរវិញដើម្បីថ្វាយចម្លើយតែព្រះនាងមិននៅទីនោះទៀតទេ។



បុត្រចេញផុតមួយសន្ទុះរស់ឮសំឡេងមួយនៅខាងក្រៅ៖ -មានអ្នកនៅខាងក្នុងទេ? ឱ្យខ្ញុំសុំទឹកផឹកបន្តិចបានទេ? រស់ចេញមកមើលហើយឃើញនារីកសិករវ័យក្មេងម្នាក់ញញឹមយ៉ាង ស្រស់មករកនាយ។នាយក៏ដួសទឹកឱ្យនាងព្រមទាំងសួរ៖ តើនាងមកពីណាដែរ? ខ្ញុំឈ្មោះនាថ។ខ្ញុំដើររកទិញកូនដូង។និយាយអីចឹងអ្នក... ហៅខ្ញុំថារស់ៗទៅ។



<ul>
<li>រស់... ចម្ការរបស់ខ្ញុំតូចណាស់។តើអ្នកដឹងទេធ្វើយ៉ាងណាទើបខ្ញុំអាចដាំដូងដប់ដើមជាប្រាំជួរហើយក្នុងមួយជួរមានបួនដើម? រស់រិះគិតមួយស្របក់រួចពន្យល់ទៅយុវនារីដោយយកមែកឈើមួយគូសលើដី៖ -នាងអាចដាំដូងទាំងដប់ដើមនោះតាមទម្រង់ផ្កាយដូចរូបនេះ៖ យុវនារីកសិករអរគុណដោយការពេញចិត្តចំពោះគំនិតដ៏ល្អនេះរួចនាងលានាយទៅវិញ។រស់សម្លឹងមើលនាងចាកចេញទៅទាំងមិនអស់ចិត្ត។</li>
</ul>




មួយអាទិត្យក្រោយមកនៅតាមដើមឈើនានាក្នុងស្រុកគេឃើញមានបិទប្រកាសផ្សាយដំណឹងក្រៀមក្រំមួយ៖ ព្រះនាងបញ្ចនាថមានព្រះរោគជាទម្ងន់ មិនមានពេទ្យហ្លួងណាព្យាបាលបានឡើយ។ ព្រះអង្គនឹងរៀបអភិសេកព្រះនាងឲ្យនរណាម្នាក់ ដែលអាចជួយសង្គ្រោះព្រះនាងបាន។ បុត្រមានគំនិតលោភលន់កាន់តែខ្លាំង។គេទៅរករស់និងសុំឱ្យជួយ គេម្តងទៀត។យប់នេះក្រោមពន្លឺព្រះចន្ទរស់បើកមើលសៀវភៅពណ៌មាសចុះឡើងៗដោយច្រាស់ច្រាល់ក្នុងចិត្ត។ទីបំផុតនាយក៏រកឃើញដំណោះស្រាយមួយ៖«អ្នកដែលចង់ព្យាបាលជំងឺមរណៈត្រូវទៅយកត្បូងគុជវេទមន្តដែលស្ថិតនៅកន្លែងដ៏ជ្រៅបំផុតនៃ បាតមហាសមុទ្រខាងកើត។បន្ទាប់មកគេត្រូវកិនរំលាយវាផ្សំនឹងទឹកសន្សើមរួចឱ្យអ្នកជំងឺផឹក»។



វគ្គទី៤ ការស្វែងរកត្បូងគុជវេទមន្ត មិនយូរប៉ុន្មាននាថនិងរស់
បានមកដល់ឆ្នេរសមុទ្រខាងកើត។នៅលើឆ្នេរដីធំល្វឹងល្វើយ
ពួកគេជួបដូនចាស់ម្នាក់ដែលហាក់ដូចជាកំពុងរង់ចាំពួកគេ។
គាត់ពោលទៅកាន់អ្នកទាំងពីរ៖ -ខ្ញុំដឹងថាពួកឯងមករកអ្វី
ហើយខ្ញុំនៅទីនេះដើម្បីជួយបង្ហាញផ្លូវ។ពួកឯងឃើញសត្វស្លាប
ពណ៌ប្រផេះទាំងពីរនោះទេ? សត្វញីនឹងនាំពួកឯងទៅរក
ត្បូងគុជវេទមន្តដែលស្ថិតនៅឯបាតសមុទ្រ។ផ្ទុយទៅវិញសត្វ
ឈ្មោលនឹងចឹកពួកឯងរហូតដល់ស្លាប់។ខ្ញុំសង្ឃឹមថាពួកឯង
នឹងជ្រើសរើសបានត្រឹមត្រូវ។ នាថសួររស់ដោយបារម្ភ៖ -រូបរាង
ពួកវាដូចគ្នាណាស់តើយើងរើសយកមួយណា? រស់ចូលទៅជិត

សត្វទាំងពីរហើយសង្កេតពិនិត្យមើលដោយយក ចិត្តទុកដាក់។ រំពេចនោះពន្លឺព្រះអាទិត្យចាំងមកលើស្លាបសត្វមួយក្បាល បង្កើតបានជាពណ៌ភ្លឺផ្លេក។រស់នឹកទៅដល់កំណាត់ចំណាំមួយក្នុងសៀវភៅពណ៌មាស។



នាយញញឹមហើយនិយាយ៖ -នេះជាសត្វឈ្មោល។វាមាន
ពណ៌ភ្លឺស្រស់ជាងសត្វញី។ រស់ក៏ដើរសំដៅទៅសត្វញីនិង
យកដៃអង្អែលវាស្រាលៗ។បក្សីឱនបន្ទាបខ្លួនតាមសម្រួលឱ្យ
អ្នកទាំងពីរឡើងជិះលើខ្នងវា។វាហោះ ឡើងតិចៗត្រដាងស្លាប
នៅលើអាកាសមួយសន្ទុះទើបបោះពួយយ៉ាងរហ័សចុះទៅក្នុង
សមុទ្រ។នាថនិងរស់រន្ធត់ជាខ្លាំងហើយតោង ស្លាបសត្វយ៉ាង
ស្អិត។ពួកគេគ្មានពេលសូម្បីតែស្រែកមួយម៉ាត់!



ពួកគេមានអារម្មណ៍ថាទឹកជ្រាបសព្វលើរាងកាយហើយឆ្ងល់ថាហេតុអ្វីក៏ពួកគេនៅតែអាចដកដង្ហើមបាន។បក្សីហែលឆ្វេលក្នុងទឹកមួយស្របក់។អ្នកទាំងពីររំភើបចិត្តជាខ្លាំងចំពោះសោភ័ណភាពដ៏ស្រស់ស្អាតរបស់ផ្កាថ្មត្រីសមុទ្រគ្រប់ប្រភេទនិងរុក្ខជាតិចម្រុះពណ៌។រំពេចនោះនាថចង្អុលទៅគ្រុំពណ៌សធំមួយ។បក្សីក៏ហែលទៅជិតដើម្បីឱ្យរស់អាចឈោងចាប់យកវាបានដោយងាយ។នៅទីបំផុតពួកគេត្រលប់មកដល់ឆ្នេរខ្សាច់វិញ។



នៅទីនោះដូនចាស់រង់ចាំពួកគេ៖ -ល្អណាស់ចៅទាំងពីរ! ឥឡូវនេះដើម្បីបើកសំបកគ្រំបានពួកឯងត្រូវស្វែងរកនរណាម្នាក់ដែលចេះដើរប៉ុន្តែមិនចេះឈានជើងត្រង់ទៅមុខសោះ... រស់គិតមួយស្របក់ទើបសម្រេចចិត្តឆ្លើយយ៉ាងជឿជាក់៖ -គឺពិតជាសត្វក្ដាម! មែនទេលោកយាយ? រំពេចនោះក្ដាមធំមួយផុសចេញពីខ្សាច់។វាសំដៅទៅគ្រំនោះនិងកៀបបំបែកសំបកគ្រំដោយតង្កៀបដ៏រឹងមាំ។គ្រាប់គុជដ៏ធំភ្លឺផ្លេកមួយបានបង្ហាញខ្លួនឡើង។



នាថឧទានដោយស្ងប់ស្ងែង៖ - ពិតជាអស្ចារ្យមែន! អ្នកបាន ជោគជ័យហើយ។អ្នកនឹងទទួលបានគុណសម្បត្តិពីព្រះរាជា។

- ខ្ញុំមិនមែនត្រូវការគុណសម្បត្តិនោះទេ។ខ្ញុំធ្វើនេះដើម្បីជួយជីវិតមនុស្សប៉ុណ្ណោះ។ រស់និងនាថថ្លែងអំណរគុណដូនចាស់ហើយលាគាត់ត្រលប់មកផ្ទះវិញ។ព្រលឹមស្រាងៗពួកគេមកដល់ក្បែរភូមិ។នាថនិយាយ៖ -ពួកយើងត្រូវបែកផ្លូវគ្នាត្រឹមនេះហើយ។ លាហើយរស់! សូមអ្នកបន្តការងារទៅមុខទៀតឱ្យបានល្អ។



វគ្គទី៥ ភ័ព្វព្រេងរបស់រស់ រស់ត្រលប់មកផ្ទះវិញទាំងនឹកមម៉ៃ ដល់នាថ។គេក្រៀមក្រំនិងរីករាយ ក្នុងពេលជាមួយគ្នា។គេដើរ ប្រមូលទឹកសន្សើមនៅតាមស្រទាប់ផ្កាទាំងឡាយនៅខាងមុខ ផ្ទះរួចកិនលម្អិតត្បូងគុជនិងផ្សំឱសថតាមការណែនាំរបស់ សៀវភៅពណ៌មាស។ពេលរៀបចំដបថ្នាំរួចហើយរស់យកវាទៅ ឱ្យបុត្រ។គេឆក់យកឱសថពីដៃរស់ដោយគ្មានពាក្យអរគុណមួយ ម៉ាត់ហើយរត់សំដៅទៅរាជវាំង។ អ្នកយាមបើកផ្លូវឱ្យគេចូល រាជដំណាក់ព្រះនាងបញ្ញនាថ។ពេលព្រះនាងយាងមកដល់បុត្រ ភ្ញាក់ផ្អើលក្នុងចិត្តមិនតិចទេដោយឃើញ ក្សត្រីមានសុខភាពល្អ ធម្មតា។គេរារែកប៉ុន្តែដាច់ចិត្តពោល៖ -នេះជាឱសថទិព្វសម្រាប់

ព្រះនាង។ ទូលព្រះបង្គំបានយកជីវិតទៅផ្សងព្រេងយកវាមក ថ្វាយ។ បញ្ចនាថជ្រួញចិញ្ចើមនិងមានបន្ទូលកាត់៖ -ឈប់ កុហកទៅ! អ្នកឯងគ្រាន់តែជាជនបោកប្រាស់ម្នាក់ប៉ុណ្ណោះ។ ខ្ញុំ បានដឹងពីល្បិចរបស់អ្នកឯងអស់ហើយ។



ព្រះនាងបែរទៅរកអ្នកយាមនិងចេញបញ្ជា៖ -ទៅរកបុរសឈ្មោះ រស់នៅក្នុងភូមិមក! ក្នុងចន្លោះពេលរង់ចាំរស់បុត្រភ័យញ័រខ្លួន ក្រោមក្រសែភ្នែកចោទប្រកាន់របស់ព្រះនាង។ទីបំផុតរស់ក៏ មកដល់។នាយរំភើបចិត្តណាស់ហើយក៏បារម្ភផងដែរដោយត្រូវ រាជវាំងកោះហៅ។ពេលឃើញព្រះនាងបញ្ជានាថនាយភ្ញាក់ផ្អើល យ៉ាងខ្លាំងនិងឧទាន៖ -នាថតើនាងនៅទីនេះធ្វើអ្វី? ប៉ុន្តែភ្លាមៗ នោះនាយក៏សម្រួលឥរិយាបថនិងឱនលំទោនចំពោះនាងដោយ ក្តីគោរព។



ពេលនោះព្រះនាងរៀបរាប់ពីការសង្ស័យនិងល្បិចទាំងឡាយ របស់ខ្លួន។រីឯរស់វិញនាយក៏ទំលាយការសម្ងាត់របស់ខ្លួននិង ទៅ យកសៀវភៅពណ៌មាសមកបង្ហាញអ្នករាល់គ្នា។បុត្រមាន ក្ដីអាម៉ាស់ យ៉ាងខ្លាំងហើយត្រូវបានគេបណ្ដេញចេញពីរាជវាំង ជារៀងរហូត។ មិនយូរប៉ុន្មាននៅតាមដើមឈើនានាគេឃើញ មានប្រកាសថ្មីមួយស្ដីអំពីដំណឹងរៀបអភិសេកព្រះនាងបញ្ញា នាថនិងនាយរស់ដែលជាទីប្រឹក្សាថ្មីរបស់ព្រះរាជា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*សៀវភៅពណ៌មាស*, Author: ស្រី សម្ផស្ស. Illustrator: Eva Calonder. Published by Sipar, © Sipar. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/